អន្តរបូរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ចរិយាពយ៉ាងរបស់ព្រះពុទ្ធ ។

website: www.hoksavann.org

ថ្ងៃទី២១ ឧសភា ២០០៨



ព្រះពុទ្ធគ្រប់ព្រះអង្គតែងមានចរិយាពយ៉ាងគឺ ពុទ្ធត្ថចរិយា ការប្រព្រឹត្តដើម្បីប្រយោជន៍ឲ្យបានត្រាស់ជាព្រះពុទ្ធ, ញាតត្ថចរិយា ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់ព្រះញាតិ, លោកត្ថចរិយា ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់សត្វលោក ឬសង្គមមនុស្ស ។ ចរិយាទី១ជាប្រយោជន៍ផ្ទាល់ខ្លួនព្រះអង្គ ចរិយាទី២និងទី៣ ជាប្រយោជន៍ព្រះញាតិនិងសត្វលោក គឺប្រយោជន៍អ្នកដទៃ ។ តាមសេចក្តីពិត មុននឹងជួយអ្នកដទៃត្រូវជួយខ្លួនឯងជាមុនសិន ។ ដូចជាជួយអ្នកដទៃដោយកម្លាំងកាយត្រូវតែខ្លួនឯងមានកម្លាំងកាយមាំមួន មានសុខភាពល្អ ។ ជួយអ្នកដទៃដោយទ្រព្យសម្បត្តិ ត្រូវតែខ្លួនមានទ្រព្យសម្បត្តិ ។ ជួយអ្នកដទៃដោយចំណេះវិជ្ជា ត្រូវតែខ្លួនឯងមានចំណេះដឹង ។ យ៉ាងណាមិញ ព្រះសម្ពុទ្ធដែលមានសមត្ថភាពអាចសំដែងធម្មទេសនាប្រោសសត្វបាន លុះត្រាតែព្រះអង្គបានត្រាស់ជាព្រះពុទ្ធជាមុនសិន ។

ចរិយាទី១នៃព្រះអង្គ គឺការកសាងឲ្យបានត្រាស់ជាព្រះពុទ្ធ ។ ព្រះអង្គបានតាំងព្រះទ័យជាអាទិទេព គឺការស្វែងរកព្រះធម៌ ដើម្បីរំដោះខ្លួនព្រះអង្គឲ្យចេញចាកទុក្ខក្នុងវដ្តសង្សារ គឺការកើតចាស់ឈឺស្លាប់ ។ គ្មានស្រឡាញ់អ្វីស្មើនឹងស្រឡាញ់ខ្លួនឡើយ បានជាព្រះពោធិសត្វខំកសាងបារមីធម៌មានទានបារមីជាដើម បានទទួលទុក្ខវេទនាអស់ពេលដ៏យូរជាច្រើនជាតិ ។ បន្ទាប់ពីបានកសាងបារមីធម៌បរិបូណ៌ហើយ នៅជាតិជាទីបំផុត ព្រះពោធិសត្វបានព្យាយាមពិសោធដោយវិធីគ្រប់បែបយ៉ាង ដើម្បីស្វែងរកការពិតនេះ ។ ដូចជាព្រះពោធិសត្វព្រះសិទ្ធត្ថ បន្ទាប់ពីបានបួសជាតាបសឥសីហើយ ព្រះអង្គបានសិក្សាពិសោធធ្វើសមាធិជាមួយគ្រូពីរនាក់ គឺអាឡ្សរតាបស និងឧទកតាបស ដែលមានឈ្មោះល្បីក្នុងសម័យនោះ ។ បន្ទាប់ពីពិសោធន៍ពុំឃើញធម៌ត្រាស់ដឹង ទើបព្រះអង្គលាអាចារ្យ

ទាំងពីរ ហើយធ្វើការពិសោធដោយខ្លួនព្រះអង្គវិញ ។ ព្រះអង្គធ្វើទុក្ករកិរិយា គឺជាអំពើដែលគេកម្រធ្វើកើត ដូចជាឯកឯងផ្ទើមតិចៗ បន្ថយចង្ហាន់ជាដើម ។ ដោយព្រះអង្គជ្រាបថា ការប្រព្រឹត្តបែបនេះជាវិធីខុសមិនអាចត្រាស់ដឹងបាន ទើបព្រះអង្គលះបង់វិធីនេះចោល ហើយប្រើបញ្ញាពិចារណាជាថ្មីទៀត ។ លទ្ធផលនៃការពិសោធ ផ្សំនឹងបារមីធម៌ដែលព្រះអង្គកសាងពីជាតិមុនៗផង ព្រះអង្គបានរកឃើញផ្លូវត្រាស់ដឹង គឺមគ្គប្រកបដោយអង្គ៨ ហើយព្រះអង្គប្រតិបត្តិតាមផ្លូវនេះ ក៏បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ។ ដូច្នេះបញ្ជាក់ថា ការត្រាស់ដឹងជាព្រះពុទ្ធជាការក្រ គឺក្រនឹងបានត្រាស់ជាព្រះពុទ្ធ ។ នៅពេលត្រាស់ដឹងឈ្មោះថា ព្រះអង្គបានរំដោះខ្លួនព្រះអង្គចេញចាកទុក្ខ មានជាតិទុក្ខជាដើមដោយដាច់ខាតហើយ ។

ចរិយាទី២នៃព្រះពុទ្ធ គឺសង្គ្រោះព្រះញាតិ ។ បន្ទាប់ពីត្រាស់ដឹងហើយ ព្រះអង្គបានយាងទៅប្រោសពុទ្ធមាតានិងពុទ្ធបិតា និងព្រះញាតិវង្សដទៃទៀត ឲ្យត្រាស់ដឹងធម៌ ហើយរួចចាកទុក្ខ មានជាតិទុក្ខជាដើម ដោយការសំដែងធម៌ទេសនា ។ កតញ្ញូការដឹងគុណជាធម៌របស់បណ្ឌិត ដូចព្រះពុទ្ធព្រះបរមគ្រូជាដើម ។ យ៉ាងណាមិញ ទំនាក់ទំនងរវាងព្រះមាតាព្រះបិតានិងព្រះញាតិវង្ស ដែលធ្លាប់មានគុណចំពោះព្រះអង្គ កាលនៅជាគ្រហស្ថព្រះអង្គបានតបគុណនេះវិញ ដោយការពន្យល់ណែនាំប្រាប់មធ្យោបាយ គឺព្រះធម៌ទៅរកការរំដោះទុក្ខ ។ ព្រះសកម្មភាពនេះរបស់ព្រះពុទ្ធ មិនឈ្មោះថាព្រះអង្គនិយមព្រះញាតិឡើយ តែជាភារកិច្ចចាំបាច់ដែលព្រះអង្គត្រូវបំពេញ ដែលជាអង្គរបស់បណ្ឌិត ។

ចរិយាទី៣របស់ព្រះពុទ្ធ គឺការសង្គ្រោះមនុស្សសត្វទូទៅ ។ ទន្ទឹមគ្នានឹងការសង្គ្រោះព្រះញាតិ ព្រះអង្គបានប្រោសមនុស្សសត្វទូទៅដោយព្រះទ័យករុណាអាណិតអាសូរមនុស្សសត្វ ដែលកំពុងវិលកើតវិលស្លាប់ក្នុងវដ្តសង្សារ ។ ត្រង់ពាក្យថា ព្រះអង្គទូន្មាននូវសត្វដែលមានឧបនិស្ស័យគួរនឹងទូន្មានបាននោះ ក្នុងន័យថា សត្វនោះមានឧបនិស្ស័យគឺធ្លាប់បានធ្វើទានសីលភាវនាពីមុនមក ទើបចាប់អារម្មណ៍ចំពោះព្រះអង្គ ទទួលយកធម៌ទេសនារបស់ព្រះអង្គទៅប្រតិបត្តិ ។ បើសត្វនោះមិនធ្លាប់ធ្វើល្អពីមុនមកទេ ពិបាកព្រះអង្គទូន្មានណាស់ មានសត្វខ្លះមិនស្តាប់មិនជឿព្រះអង្គ ដោយពួកគេប្រកាន់ទិដ្ឋិ មានជំនឿមួយយ៉ាងមាំហើយ ត្រង់នេះហើយដែលពោលថា សត្វគ្មានឧបនិស្ស័យ គួរឲ្យព្រះអង្គទូន្មានបានឡើយ ។ សេចក្តីពិត ព្រពុទ្ធគ្រប់ព្រះអង្គតែមានការអាណិតអាសូរចំពោះសព្វសត្វជាទូទៅមិនរើសមុខ ប៉ុន្តែលុះតែសត្វនោះចេះជួយខ្លួនឯងផង ទើបព្រះអង្គប្រោសបាន ។ ពាក្យថាសត្វ ដែលប្រើក្នុងវិធីនេះ គឺហៅបានចំពោះអ្នកដែលកើតក្នុងភពទាំងបី គឺអ្នកដែលបានជាតិចិត្តក្នុងភព ដូចជាមនុស្សទេវតាព្រហ្មជាដើម ឯសត្វតិរច្ឆាន ក៏រាប់បញ្ចូលក្នុងពាក្យនេះដែរ ។ ប្រើពាក្យតែមួយ គឺព្រះពុទ្ធប្រោសសត្វ ហៅបានអ្នកដែលទៅកើតក្នុងភពទាំងអស់ ។ មានតែព្រះនិព្វានទេ ដែលលែងឈ្មោះថាសត្វ

ព្រោះព្រះនិព្វានរលត់តណ្ហាក្នុងភពហើយ ។

ដូចបានពោលមកហើយ ព្រះអង្គបានកសាងអស់ពេលដ៏យូរ រហូតបានត្រាស់ជាព្រះពុទ្ធនេះ គឺបំណងប្រោសសត្វឲ្យចេញចាកទុក្ខ ចំណែកព្រះបច្ចេកពុទ្ធបានសំរេចព្រះអរហន្តតែខ្លួនលោក ពុំមានសមត្ថភាពសំដែងធម៌ទេសនាប្រោសសត្វបានឡើយ ។ ដោយសារការផ្សព្វផ្សាយធម៌ទេសនារបស់ព្រះអង្គនេះហើយ បានជាមនុស្សក្នុងលោករាប់រយលាននាក់ បានទទួលកាន់ព្រះពុទ្ធសាសនា ហើយសព្វថ្ងៃនេះ ព្រះពុទ្ធសាសនាបានលូតលាស់យ៉ាងខ្លាំងនៅទ្វីបអឺរ៉ុប និងនៅសហរដ្ឋអាមេរិក ។៚

❄ ❄

❄